ឯកសារស្រាវជ្រាវសង្ខេប

រដ្ឋសភា គណៈកម្មការទី៦ ស្តីពីនីតិកម្ម និងយុត្តិធម៌

# កំណែទម្រង់ច្បាប់ និងប្រព័ន្ធយុត្តិធម៌នៅកម្ពុជា


អ្នកទទួលខុសត្រូវស្រាវជ្រាវ: **លោកស្រី វណ្ណា រី** (កម្មសិក្សាការីមកពីរដ្ឋសភា)

ដោយមានការចូលរួមពី: **កញ្ញា សត្យារដ្ឋ ពិជិតប៉ាត្យា** (អ្នកស្រាវជ្រាវពីប្រទេសថៃ)

**លោក លី យ៉ាសាក់**

**លោក ជី ទេវិទ្ធិ**



ខែកុម្ភៈ ឆ្នាំ ២០១៦

វិទ្យាស្ថានសភាកម្ពុជា

# កំណត់សម្គាល់

វិទ្យាស្ថានសភាកម្ពុជា (វ.ស.ក) គឺជាស្ថាប័នឯករាជ្យមួយដែលផ្តល់ការគាំទ្រដល់សភាកម្ពុជា តាមរយៈការផ្តល់នូវឯកសារស្រាវជ្រាវទៅតាមសំណើរបស់សមាជិក-សមាជិកា និងគណៈកម្មការជំនាញរបស់រដ្ឋសភា-ព្រឹទ្ធសភា ដែលមានការវិភាគទៅលើបញ្ហាដែលកំពុងតែកើតមាននៅពេលបច្ចុប្បន្ន និងដែលអាចនឹងកើតឡើង នាពេលអនាគតលើប្រធានបទការរៀបចំច្បាប់ និងគោលនយោបាយសាធារណៈ។ ឯកសារទាំងនេះផ្តល់នូវព័ត៌មានផ្សេងៗដែលពាក់ព័ន្ធនឹងការងារសភា និងការងារមណ្ឌល ឬភូមិភាគរបស់សមាជិក-សមាជិការសភា ក៏ប៉ុន្តែរាល់អត្ថន័យដែលមាននៅក្នុងឯកសារទាំងនេះមិនមែនតំណាងឬឆ្លុះបញ្ចាំងអំពីទស្សនៈផ្ទាល់របស់វិទ្យាស្ថាន សភាកម្ពុជាសភា ឬសមាជិក-សមាជិកាណាម្នាក់នោះឡើយ។

ខ្លឹមសារនៃឯកសារទាំងនេះមានកំណត់នូវកាលបរិច្ឆេទរៀបចំច្បាស់លាស់ និងអាចប្រើប្រាស់សម្រាប់ តែជាឯកសារយោងប៉ុណ្ណោះ។ ឯកសារទាំងនេះមិនមានគោលបំណងផ្តល់ប្រឹក្សាផ្នែកច្បាប់ ឬទៅលើគោល នយោបាយណាមួយឡើយ ហើយក៏មិនបានធ្វើការសិក្សាអោយបានគ្រប់ប្រធានបទ ឬរាល់ខ្លឹមសារលម្អិតដែល ពាក់ព័ន្ធនឹងបញ្ហាដែលបានលើកឡើងនោះដែរ។

ខ្លឹមសារនៃឯកសារស្រាវជ្រាវសង្ខេបនេះ ស្ថិតក្រោមច្បាប់ជាធរមានរបស់កម្ពុជា និងកិច្ចព្រមព្រៀងអន្តរជាតិស្តីពីសិទ្ធិអ្នកនិពន្ធ។ រាល់ការរៀបចំឡើងវិញដោយដកស្រង់នូវផ្នែកណាមួយ ឬខ្លឹមសារទាំងស្រុងនៃឯកសារស្រាវជ្រាវនេះត្រូវមានការអនុញ្ញាតពីវិទ្យាស្ថាន។

រក្សាសិទ្ធិ ឆ្នាំ២០១៦ វិទ្យាស្ថានសភាកម្ពុជា (វ.ស.ក)។

# មាតិកា


សេចក្តីសង្ខេប ........................................ 1

**១.** សេចក្តីផ្តើម ........................................ 3

២. ប្រព័ន្ធច្បាប់ និងយុត្តិធម៌នាពេលបច្ចុប្បន្ននៅប្រទេសកម្ពុជា ........................................ 4

២.១ ប្រព័ន្ធច្បាប់ ........................................ 4

២.១.១ ប្រភពនៃច្បាប់កម្ពុជា ........................................ 4

២.១.២ ដំណើរការនៃការបង្កើតច្បាប់ ........................................ 6

២.១.៣ ក្រុមប្រឹក្សាធម្មនុញ្ញ ........................................ 6

២.២ ប្រព័ន្ធតុលាការ ........................................ 7

២.២.១ ស្ថាប័នគ្រប់គ្រង និង គាំទ្រដល់ប្រព័ន្ធតុលាការ ........................................ 8

២.៣. កិច្ចខិតខំប្រឹងប្រែងកំណែទម្រង់ច្បាប់ និងយុត្តិធម៌ ........................................ 8

៣. បញ្ហាប្រឈម និងសំណើរគោលនយោបាយ ........................................ 10

៣.១. បញ្ហាប្រឈមនៅក្នុងកំណែទម្រង់ច្បាប់ និងយុត្តិធម៌ ........................................ 10

៣.២. សំណើរគោលនយោបាយ ........................................ 11

សេចក្តីសន្និដ្ឋាន ........................................ 15

## សេចក្ដីសង្ខេប

ចាប់តាំងពីឆ្នាំ២០០៣មក រាជរដ្ឋាភិបាលកម្ពុជាបានដាក់ចេញទាំងយុទ្ធសាស្ត្រ និងផែនការសកម្មភាពដើម្បីកំណែទម្រង់ច្បាប់ និងយុត្តិធម៌។ សមិទ្ធផលដែលគួរឲ្យកត់សម្គាល់ជាច្រើនរួមមានៈ ការបង្កើតនូវស្ថាប័ននានា ឧបករណ៍ច្បាប់ និងការកសាងសមត្ថភាពត្រូវបានធ្វើឡើងក្នុងគោលបំណងពង្រឹងតុលាការ រួមទាំងធ្វើទំនើបកម្មប្រព័ន្ធច្បាប់ និងយុត្តិធម៌។ តែទោះបីជាយ៉ាងណាក៏ដោយ កិច្ចប្រឹងប្រែងនៃកិច្ចកំណែទម្រង់នេះនៅមានបញ្ហាប្រឈមជាច្រើន។[1]

- ធនធានមនុស្សៈ
  - មានការខ្វះខាតចំនួនចៅក្រម ព្រះរាជអជ្ញា ក្រឡាបញ្ជី និងមន្ត្រីរដ្ឋបាលនៅក្រសួងយុត្តិធម៌ និងតុលាការរាជធានី ខេត្ត។
  - មានការខ្វះខាតតុលាការជំនាញដូចជាតុលាការការងារ តុលាការអនីតិជន តុលាការពាណិជ្ជកម្ម និងតុលាការរដ្ឋបាល ដោយសារចំនួននៃការបណ្ដុះបណ្ដាលចៅក្រមនៅមាន កម្រិត។
  - មានការខ្វះខាតមន្ត្រីចុះបញ្ជីសំណុំរឿងក្ដីតាមប្រព័ន្ធចុះបញ្ជីថ្មី (គម្រោងតុលាការគំរូ) មិនទាន់ឆ្លើយតបទៅនឹងការងារគ្រប់គ្រងរឿក្ដីឲ្យល្អប្រសើរ។

- ការគ្រប់គ្រងសមត្ថភាពស្ថាប័ន
  - មានការខ្វះខាតអាគារការិយាល័យនៅតាមក្រសួង តុលាការខេត្ត និងការិយាល័យសម្រាប់ចៅក្រម និងព្រះរាជអជ្ញា។
  - ខ្វះអាគារក្នុងដំណើរការយន្តការដោះស្រាយជម្លោះ។
  - ថវិកាមានកម្រិតសម្រាប់ក្រសួងយុត្តិធម៌ និងតុលាការរាជធានី ខេត្ត
  - មានការខ្វះខាតមេធាវីក្នុងការផ្ដល់ជំនួយផ្នែកច្បាប់
  - មានការខ្វះខាតថវិកាក្នុងដំណើរការក្ដីពាក់ព័ន្ធព្រហ្មទណ្ឌ
  - ការចុះមូលដ្ឋានផ្ទាល់នៅមានកម្រិត

រាជរដ្ឋាភិបាលកម្ពុជាមានការប្ដេជ្ញាចិត្តក្នុងការបន្តការអនុវត្តកំណែទម្រង់ ដែលនឹងនាំមកលទ្ធផលបន្ថែមទៀតក្នុងការអនុវត្តយុទ្ធសាស្ត្រកំណែទម្រង់ច្បាប់ និងយុត្តិធម៌ ដែលបានដាក់ចេញតាំងពីឆ្នាំ២០០៣។ ខាងក្រោមនេះ គឺជាការផ្ដល់នូវជម្រើសគោលនយោបាយនេះក្នុងការបង្កើតល្បឿននៃកំណែទម្រង់នេះ។

[1] RGC, National Strategic Development Plan 2014-2018, pp. 9-12.

- បន្តបង្កើននូវធនធាន ទាំងផ្នែកហេដ្ឋារចនាសម្ព័ន្ធ និងថវិកា ដល់តុលាការរាជធានី ខេត្ត។
- បន្តបង្កើនសមត្ថភាព និងបង្កើនចំនួនចៅក្រម ព្រះរាជអជ្ញា និងមន្ត្រីតុលាការដោយធ្វើការជ្រើសរើសក្នុងចំណោមប្រជាពលរដ្ឋកម្ពុជាវ័យក្មេង និងស្វាហាប់ តាមរយៈរាជបណ្ឌិតសភាវិជ្ជាជីវៈតុលាការ និងមជ្ឈមណ្ឌលបណ្តុះបណ្តាលមេធាវី។
- បន្តបង្កើនការពង្រឹងក្រមសីលធម៌ និងវិធានការណ៍វិន័យរបស់តុលាការ ប្រឆាំងទៅនឹងចៅក្រម ព្រះរាជអជ្ញា និងអ្នកពាក់ព័ន្ធ ដែលប្រព្រឹត្តខុសក្រមសីលធម៌ និងបន្តប្រយុទ្ធប្រឆាំងអំពើពុករលួយ។
- ពង្រីក និងពង្រឹងសេវា និងប្រើប្រាស់យន្តការដោះស្រាយវិវាទក្រៅប្រព័ន្ធតុលាការ។ កិច្ចប្រឹងប្រែងក្នុងការបង្កើត "ផ្ទះយុត្តិធម៌( Maisons de la Justice )" នៅតាមក្រុង ស្រុក ខណ្ឌ និង "គណៈកម្មាធិការដោះស្រាយវិវាទឃុំ សង្កាត់" នៅតាមថ្នាក់ឃុំ សង្កាត់ គួរតែត្រូវបានបន្ត និងពង្រីកបន្ថែម។
- បង្កើនចំនួនសាលាឧទ្ធរណ៍។
- កាត់បន្ថយចំនួនអ្នកជាប់ពន្ធនាគារ ដោយអនុវត្តវិធានការណ៍ផ្តន្ទាទោសប្រកបដោយការច្នៃប្រឌិត និងលើកទឹកចិត្តការប្រើប្រាស់យន្តការដោះស្រាយវិវាទក្រៅប្រព័ន្ធតុលាការ។

## ១. សេចក្តីផ្តើម

កំណែទម្រង់ច្បាប់ និងយុត្តិធម៌នៅតែជារបៀបវារៈសំខាន់របស់រាជរដ្ឋាភិបាលកម្ពុជានីតិកាលទី ៥ នេះ។ ចាប់តាំងពីឆ្នាំ២០០៣មក រាជរដ្ឋាភិបាលកម្ពុជាបានព្យាយាមកែលម្អប្រព័ន្ធច្បាប់ និងយុត្តិធម៌តាមរយៈ កម្មវិធីកំណែទម្រង់នានា។ យុទ្ធសាស្ត្រសម្រាប់ការអនុវត្តកំណែទម្រង់នេះត្រូវបានអនុម័តដោយគណៈ រដ្ឋមន្ត្រីនៃរាជរដ្ឋាភិបាលកម្ពុជា។[2] យុទ្ធសាស្ត្រនៃកំណែទម្រង់នេះគឺស្ថិតនៅជុំវិញបញ្ហាសិទ្ធិមនុស្ស នីតិរដ្ឋ និងគោលការណ៍នៃការបែងចែកអំណាច ។[3] ជាមួយគ្នាផងដែរ ផែនការសកម្មភាពដើម្បីអនុវត្ត យុទ្ធសាស្ត្រនេះក៏ត្រូវបានអនុម័តដោយគណៈរដ្ឋមន្ត្រីកាលពីឆ្នាំ២០០៥។ រាជរដ្ឋាភិបាលកម្ពុជានៅតែបន្តផ្តល់អាទិភាពខ្លាំងនៅក្នុងយុទ្ធសាស្ត្រកំណែទម្រង់ ដើម្បីលើកកម្ពស់កំណែទម្រង់ច្បាប់ និងតុលាការនៅក្នុងប្រទេសកម្ពុជា។ ការអនុវត្តយុទ្ធសាស្ត្រកំណែទម្រង់នៅតែកំពុងបន្ត។ ឧទាហរណ៍ យុទ្ធសាស្ត្រ និងសកម្មភាពទាំងនេះត្រូវបានដាក់ចេញនៅក្នុងផែនការអភិវឌ្ឍន៍យុទ្ធសាស្ត្រជាតិ២០១៤-២០១៨ និងយុទ្ធសាស្ត្រចតុកោណដំណាក់កាលទី៣។

ប្រព័ន្ធច្បាប់ទំនើបនៅប្រទេសកម្ពុជាត្រូវបានទទួលឥទ្ធិពលយ៉ាងខ្លាំង ពីប្រព័ន្ធច្បាប់របស់ប្រទេសបារាំង (ប្រព័ន្ធច្បាប់ស៊ីវិល) ដោយសារប្រទេសកម្ពុជាធ្លាប់ស្ថិតក្រោមអាណានិគមប្រទេសបារាំងចាប់ពីឆ្នាំ១៨៦៣ ដល់ ១៩៥៣។ ប្រព័ន្ធច្បាប់នេះត្រូវបានបន្តអនុវត្តនៅក្នុងប្រទេសកម្ពុជារហូតដល់ឆ្នាំ១៩៧៥។ ពីឆ្នាំ ១៩៧៥-១៩៧៩ ប្រព័ន្ធច្បាប់របស់ប្រទេសកម្ពុជាត្រូវបានបំផ្លាញស្ទើរតែទាំងស្រុង ក្នុងរបបខ្មែរក្រហម ហើយអ្នកអនុវត្តច្បាប់ភាគច្រើនដូចជាចៅក្រម ព្រះរាជអជ្ញា មេធាវីត្រូវបានសម្លាប់។ ជាក់ស្តែង អ្នកដែលនៅរស់រានមានជីវិតពីរបបភ័យខ្លាចនេះ ហើយដែលបានទទួលការបណ្តុះបណ្តាលផ្នែកច្បាប់មុនឆ្នាំ១៩៧៥ មានចំនួនតែ ៧ នាក់ប៉ុណ្ណោះ ហើយអ្នកទាំងនោះបានក្លាយជាអ្នកកសាងរៀបចំប្រព័ន្ធច្បាប់ និងយុត្តិធម៌ឡើងវិញ ពីចំណុចចាប់ផ្តើមដោយគ្មានអ្វីសោះ។[4] នៅក្នុងដំណាក់កាលរបស់សម័យអ៊ុនតាក់ចាប់ពីឆ្នាំ១៩៩១ ដល់ ១៩៩៣ ច្បាប់មួយចំនួនត្រូវបានអនុម័តឲ្យប្រើប្រាស់ ដែលរួមមានច្បាប់ព្រហ្មទណ្ឌ ច្បាប់ពាក់ព័ន្ធនឹងតុលាការ ច្បាប់សារព័ត៌មាន ។ល។[5] បន្ទាប់ពីការបោះឆ្នោតជាសាកលក្នុងឆ្នាំ១៩៩៣ ប្រទេសកម្ពុជាបានបើកព្រំដែនរបស់ខ្លួន និងធ្វើសេរីភាវូបនីយកម្មសេដ្ឋកិច្ចរបស់ខ្លួន និងទទួលនូវជំនួយអភិវឌ្ឍន៍ផ្លូវការជាច្រើនពី

---

[2] The Danish Institute for Human Rights (DIHR), "Implementation of Legal and Judiciary Reform in Cambodia," The Evaluation of DIHR Partnership Programme with General Secretariat of Council of Legal and Judicial Reform (CLJR), 2012, p. 8.

[3] Ibid.

[4] Tom Fawthrop and Helen Jarvis, trans., *Getting away with Genocide?, Elusive Justice and the Khmer Rouge Tribunal,* (Sydney: UNSW Press, 2005), pp. 48-49.

[5] Destination Justice, accessed 14 February 2016, http://www.chbab.net/chbab-net-in-english/about-the-cambodian-legal-system-en.

បរទេស ដើម្បីគាំទ្រដល់ការកសាងប្រទេសជាតិ។ សកម្មភាពទាំងនេះ និងការបង្កើតសាលាក្ដីខ្មែរក្រហមបាន ធ្វើឲ្យប្រទេសកម្ពុជាស្រូបយកនៅការអនុវត្តបែបអង់គ្លូសាក់សុង (Common Law) មួយចំនួនទៅក្នុងប្រព័ន្ធ ច្បាប់ និងយុត្តិធម៌របស់ខ្លួន។[6] ក្នុងន័យនេះ ប្រព័ន្ធច្បាប់នៅកម្ពុជាត្រូវបានសង្កេតឃើញថាជាប្រព័ន្ធកូនកាត់ ដែលទទួលឥទ្ធិពលទាំងប្រព័ន្ធច្បាប់ស៊ីវិល និងប្រព័ន្ធអង់គ្លូសាក់សុង ។[7]

ឯកសារស្រាវជ្រាវសង្ខេបនេះ នឹងផ្ដល់ព័ត៌មានអំពីបច្ចុប្បន្នភាពអំពីប្រព័ន្ធច្បាប់ និងយុត្តិធម៌នៅក្នុងប្រទេស កម្ពុជា។ ឯកសារនេះក៏នឹងពិនិត្យមើលផងដែរនៅបញ្ហា និងការប្រឈម ដែលតុលាការរាជធានី ខេត្ត កំពុង ប្រឈម ជាមួយនឹងអនុសាសន៍កែលម្អមួយចំនួន។

## ២. ប្រព័ន្ធច្បាប់ និងយុត្តិធម៌នាពេលបច្ចុប្បន្ននៅប្រទេសកម្ពុជា

### *២.១ ប្រព័ន្ធច្បាប់*

#### ២.១.១ ប្រភពនៃច្បាប់កម្ពុជា

ប្រភពនៃច្បាប់កម្ពុជារួមមានទាំងប្រភពផ្ទាល់ និងប្រភពមិនផ្ទាល់។[8] ប្រភពផ្ទាល់សំដៅលើឧបករណ៍ច្បាប់ទាំង អស់ដែលអនុម័ត ឬចេញដោយអង្គាធរមានសមត្ថកិច្ចរបស់រដ្ឋ រីឯប្រភពមិនផ្ទាល់សំដៅទៅលើ "ប្រពៃណី ទំនៀមទំលាប់ មនសិការ សមភាព ការសម្រេចរបស់តុលាការ អង្គាកណ្ដាល និងជំនឿសាសនា"។[9] ក្នុងរឿង ក្ដីស៊ីវិល ប្រសិនបើច្បាប់មានភាពចន្លោះប្រហោងពាក់ព័ន្ធនឹងរឿងក្ដី តុលាការអាចបន្តដំណើរការសវនការក្ដី និងធ្វើការកាត់ក្ដីដោយឈរលើមូលដ្ឋានប្រពៃណី ទំនៀមទំលាប់ មនសិការ និងសមភាព។

---

[6] Ibid.

[7] Peng, Hor; Phallack, Kong & Menzel, Jorg. 2012. *Introduction to Cambodian Law*. Published by Konrad-Adenauer-Stiftung. p. 8

[8] Ibid.

[9] Ibid. P.8-9

## ប្រភពនៃឋានានុក្រមច្បាប់នៅក្នុងប្រទេសកម្ពុជា




*ប្រភព:* Peng, Hor; Phallack, Kong & Menzel, Jorg, *Introduction to Cambodian Law*. Published by Konrad-Adenauer-Stiftung, 2012

ច្បាប់អន្តរជាតិត្រូវបានចាត់ទុកជាប្រភពនៃច្បាប់នៅក្នុងប្រទេសកម្ពុជាដែរ។ បើយោងតាមមាត្រា២៦ នៃរដ្ឋធម្មនុញ្ញកម្ពុជា រាល់សន្ធិសញ្ញា និងអនុសញ្ញាអន្តរជាតិត្រូវចុះព្រហស្តលេខា និងផ្តល់សច្ចាប័នដោយព្រះមហាក្សត្របន្ទាប់ពីបានអនុម័តដោយសភា។[10] មិនមានការបង្ហាញជាក់លាក់អំពីឋានានុក្រមនៃច្បាប់អន្តរជាតិទេ។

[10] Constitution of the Kingdom of Cambodia, Art. 26.

ប៉ុន្តែ ដោយសារច្បាប់នេះត្រូវទទួលការអនុម័តពីសភា និងផ្តល់សច្ចាប័ន ដូច្នេះវាអាចត្រូវបានចាត់ទុកថាជាច្បាប់ក្នុងស្រុកដែរ។[11]

### ២.១.២ ដំណើរការនៃការបង្កើតច្បាប់

ការបង្កើតច្បាប់អាចផ្តួចផ្តើមដោយរដ្ឋសភា ព្រឹទ្ធសភា និងរាជរដ្ឋាភិបាល។ បន្ទាប់មកច្បាប់ដែលបានធ្វើសេចក្តីព្រៀងរួចនោះត្រូវដាក់ជូនគណៈកម្មការជំនាញរដ្ឋសភាដើម្បីពិនិត្យ។ បន្ទាប់ពីការពិភាក្សារួច គណៈកម្មការជំនាញនឹងរាយការណ៍ទៅជូនសមាជិកទាំងអស់នៃរដ្ឋសភា និងដាក់ជូនសភាពេញអង្គដើម្បីសុំការអនុម័ត។ បន្ទាប់មក ច្បាប់ដែលបានព្រៀងរួចនោះត្រូវបញ្ជូនទៅកាន់ព្រឹទ្ធសភាដើម្បីពិនិត្យនិងផ្តល់យោបល់។ ក្នុងដំណាក់កាលនេះ ច្បាប់ដែលបានពង្រាងអាចបញ្ជូនទៅវិញទៅមកបាន ប្រសិនបើចាំបាច់។ ព្រឹទ្ធសភា ជាទូទៅ មានរយៈពេលមួយខែ (តែក្នុងករណីប្រញាប់ មានរយៈពេល ៥ ថ្ងៃ) ក្នុងការពិនិត្យសេចក្តីព្រៀងច្បាប់នោះ។ រដ្ឋសភាមានឆន្ទានុសិទ្ធិក្នុងការទទួលយក ឬបដិសេធន៍យោបល់របស់ព្រឹទ្ធសភា។ នៅពេលដែលពិនិត្យរួចហើយ (ដោយផ្តល់យោបល់ និងពិភាក្សាដោយសភាទាំងពីរ រដ្ឋសភាអាចអនុម័តសេចក្តីព្រៀងច្បាប់នោះ និងបញ្ជូនមកព្រះមហាក្សត្រដើម្បីប្រកាសដាក់ឲ្យប្រើប្រាស់ មុនពេលចូលជាធរមាន (រយៈពេល ១០ ថ្ងៃនៅក្នុងរាជធានីភ្នំពេញ និង ២០ ថ្ងៃ ទូទាំងប្រទេស)។ ច្បាប់ខ្លះ នៅពេលដែលមានការប្រញាប់ អាចចូលជាធរមានភ្លាមបន្ទាប់ពីប្រកាសដាក់ឲ្យប្រើប្រាស់។ ក្នុងករណីខ្លះ ក្រុមប្រឹក្សាធម្មនុញ្ញអាចពិនិត្យធម្មនុញ្ញភាពនៃច្បាប់នេះ។[12]

### ២.១.៣ ក្រុមប្រឹក្សាធម្មនុញ្ញ

ក្រុមប្រឹក្សាធម្មនុញ្ញគឺជាស្ថាប័នឯករាជ្យ ដែលធានានូវធម្មនុញ្ញភាពរបស់ច្បាប់ ហើយក្រុមប្រឹក្សាធម្មនុញ្ញនេះមានសមត្ថកិច្ចក្នុងការបកស្រាយរដ្ឋធម្មនុញ្ញ និងច្បាប់ដែលអនុម័តដោយរដ្ឋសភា។ ក្រុមប្រឹក្សាធម្មនុញ្ញមានសមាជិក ៩ រូប និងអណ្តតិ ៩ ឆ្នាំ។ ក្នុងចំណោមសមាជិកទាំងនោះ ៣ រូបត្រូវតែងតាំងដោយព្រះមហាក្សត្រ ៣ រូបពីរដ្ឋសភា និង ៣ រូបទៀតពីឧត្តមក្រុមប្រឹក្សាអង្គចៅក្រម។ មួយភាគបី នៃសមាជិកត្រូវធ្វើការផ្លាស់ប្តូរនៅរៀងរាល់ ៣ ឆ្នាំ។[13] ក្រុមប្រឹក្សាធម្មនុញ្ញក៏មានសមត្ថកិច្ចក្នុងការដោះស្រាយជម្លោះដែលពាក់ព័ន្ធនឹងការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ និងព្រឹទ្ធសភាដែរ។[14]

---

[11] Destination Justice, accessed 14 February 2016, http://www.chbab.net/chbab-net-in-english/about-the-cambodian-legal-system-en.

[12] Constitution of the Kingdom of Cambodia, Art. 91 New, 92, 93 New, 113 New and 136 New

[13] Constitution of the Kingdom of Cambodia, Arts. 136-137.

[14] Constitution of the Kingdom of Cambodia, Art. 136.

## *២.២ ប្រព័ន្ធតុលាការ*

យោងតាមរដ្ឋធម្មនុញ្ញ អំណាចបីត្រូវបានបែងចែកដាច់ពីគ្នា៖ នីតិបញ្ញត្តិ នីតិប្រតិបត្តិ និងតុលាការ ហើយមានភាពឯករាជ្យពីគ្នា។ ព្រះមហាក្សត្រជាអ្នកធានានូវឯករាជ្យភាពនៃតុលាការ ហើយឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រមត្រូវជួយព្រះមហាក្សត្រ ដើម្បីធានាឯករាជ្យភាពរបស់តុលាការ។[15] ប្រព័ន្ធតុលាការ មានបីថ្នាក់ ដែលរួមមាន តុលាការរាជធានី ខេត្ត (ថ្នាក់ទី១) សាលាឧទ្ធរណ៍ (ថ្នាក់ទី២) និងតុលាការកំពូល (ថ្នាក់ទី៣)។[16] តុលាការរាជធានី ខេត្ត និងសាលាឧទ្ធរណ៍ពិនិត្យមើលទាំងអង្គហេតុ និងអង្គច្បាប់ ក្នុងការកាត់ក្តី។ ចំណែកឯតុលាការកំពូល នៅពេលកាត់ក្តីដោយអង្គចៅក្រម ៥ រូប តុលាការកំពូលពិនិត្យមើលតែអង្គច្បាប់ទេ។ ក្នុងករណីកាត់ក្តីដោយអង្គចៅក្រម ៩រូប តុលាការកំពូលនឹងពិនិត្យមើលទាំងអង្គហេតុ និងអង្គច្បាប់។មាត្រា៨ នៃច្បាប់ស្តីពីការរៀបចំតុលាការ បានចែងថា តុលាការគ្រប់ថ្នាក់ទាំងអស់ត្រូវអមដោយការិយាល័យព្រះរាជអាជ្ញាមួយ។




[15] Constitution of the Kingdom of Cambodia, Art. 132.
[16] Law on Judicial Organization (2014)

| | | |
|---|---|---|
| នាយកដ្ឋាន ២ ៖ ស៊ីវិល និងព្រហ្មទណ្ឌ | | តុលាការការងារ និងតុលាការពាណិជ្ជកម្ម |

*ប្រភព៖ វិទ្យាស្ថានខ្មែរដើម្បីលទ្ធិប្រជាធិបតេយ្យ*

២.២.១ ស្ថាប័នគ្រប់គ្រង និង គាំទ្រដល់ប្រព័ន្ធតុលាការ

ឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រមមានសមត្ថកិច្ចក្នុងការតែងតាំង ផ្លាស់ប្តូរ និងបណ្តេញរាល់ចៅក្រម និងព្រះរាជអាជ្ញាតាមសំណើររបស់រដ្ឋមន្ត្រីក្រសួងយុត្តិធម៌។ ឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រមក៏មានសមត្ថកិច្ចផងដែរក្នុងការចាត់វិធានការណ៍វិន័យប្រឆាំងនឹងចៅក្រម និងព្រះរាជអាជ្ញាគ្រប់កម្រិត ដែលមានការធ្វេសប្រហែសក្នុងការបំពេញការងារ។[17] រដ្ឋធម្មនុញ្ញតម្រូវឲ្យស្ថាប័នមួយនេះធានានូវឯករាជ្យភាពរបស់តុលាការ។ ម្យ៉ាងវិញទៀត ក្រសួងយុត្តិធម៌មានតួនាទីជាអ្នកតាមដានពិនិត្យមើលពន្ធធនាគារ និងធានាថាសេចក្តីព្រាងច្បាប់នានាស្របទៅតាមច្បាប់ដែលនៅមាន ។ ក្រសួងយុត្តិធម៌ក៏ត្រូវបានតម្រូវឲ្យរក្សាលិខិតថ្កោលទោស។[18]

## *២.៣. កិច្ចខិតខំប្រឹងប្រែងកំណែទម្រង់ច្បាប់ និងយុត្តិធម៌*

នៅចន្លោះឆ្នាំ២០០៣ និង២០០៥ រាជរដ្ឋាភិបាលកម្ពុជាបានរៀបចំបង្កើតឯកសារសំខាន់ចំនួនពីរពាក់ព័ន្ធនឹងកំណែទម្រង់ច្បាប់ និងយុត្តិធម៌ ដែលឯកសារទាំងពីរនេះមាន៖ យុទ្ធសាស្ត្រកំណែទម្រង់ច្បាប់និងតុលាការ និងផែនការសកម្មភាពសម្រាប់អនុវត្តយុទ្ធសាស្ត្រនេះ។[19] គោលដៅយុទ្ធសាស្ត្រចំនួន៧ ត្រូវបានកំណត់នៅក្នុងយុទ្ធសាស្ត្រកំណែទម្រង់ដែលរួមមាន៖ ១) លើកកម្ពស់សិទ្ធិសេរីភាពបុគ្គល ២) ទំនើបកម្មក្របខណ្ឌច្បាប់ ៣) បង្កើនការផ្សព្វផ្សាយពត៌មានពាក់ព័ន្ធនឹងច្បាប់ និងវិស័យយុត្តិធម៌ ៤) លើកកម្ពស់ដំណើរការច្បាប់ និងសេវាផ្សេងៗទៀត ៥) បង្កើនសេវាយុត្តិធម៌ ៦) បង្កើនដំណើរការដោះស្រាយវិវាទក្រៅប្រព័ន្ធតុលាការ និង ៧) ពង្រឹងអាណត្តិ និងការបំពេញការងាររបស់ស្ថាប័នច្បាប់និងយុត្តិធម៌។[20] ដើម្បីសម្រេចឲ្យបាននូវគោលដៅទាំង៧ខាងលើ រាជរដ្ឋាភិបាលក៏បានបង្កើតផែនការសកម្មភាព ដែលមានសកម្មភាពអាទិភាពចំនួន៩៧។ នៅក្នុងផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ២០១៤-២០១៨ រាជរដ្ឋាភិបាលកម្ពុជា បានបង្ហាញអំពីការប្តេជ្ញាចិត្តក្នុងការបន្តការអនុវត្តគោលដៅទាំង៧ចំណុចសម្រាប់កំណែទម្រង់ច្បាប់ និងយុត្តិធម៌។

[17] Law on Organization and Functioning of Supreme Council of Magistracy. (2014)
[18] Law on Establishment of MoJ (1996) and Anukret on Organization and Function of MoJ (2000).
[19] Peng, Hor; Phallack, Kong & Menzel, Jorg. 2012. *Introduction to Cambodian Law*. Published by Konrad-Adenauer-Stiftung. p. 17.
[20] Ibid., p.20.

យុទ្ធសាស្ត្រចតុកោណ ដំណាក់កាលទីបី បានកំណត់នូវជោគជ័យមួយចំនួននៅក្នុងវិស័យកំណែទម្រង់ច្បាប់ និងយុត្តិធម៌កន្លងមក ដែលរួមមាន៖[21]

- ការធ្វើទំនើបកម្មក្របខណ្ឌច្បាប់ ជាពិសេស ការអនុម័តក្រមព្រហ្មទណ្ឌថ្មី ក្រមរដ្ឋប្បវេណី ក្រមនីតិវិធីរដ្ឋប្បវេណី ជាដើម។
- លើកកម្ពស់ការផ្សព្វផ្សាយច្បាប់ និងការអនុវត្តច្បាប់ តាមរយៈការអប់រំផ្នែកច្បាប់ និងវគ្គហ្វឹកហ្វឺនដល់មន្ត្រីពាក់ព័ន្ធ និង មន្ត្រីអនុវត្តច្បាប់។
- បង្កើនការពង្រឹងទាំងសមត្ថភាពវិជ្ជាជីវៈ និងគណនេយ្យភាពរបស់ចៅក្រម និងព្រះរាជអាជ្ញា។
- បង្កើនថវិកាជាបណ្តើរៗដល់ប្រព័ន្ធយុត្តិធម៌។
- ពង្រីកយន្តការដោះស្រាយវិវាទក្រៅប្រព័ន្ធតុលាការ ដែលរួមទាំងការដាក់ឲ្យដំណើរការមណ្ឌលសេវាកម្មច្បាប់ និងបង្កើតមជ្ឈមណ្ឌលជាតិនៃមជ្ឈត្តការពាណិជ្ជកម្ម។

ក្រៅពីនេះ ផ្នែកផ្សេងទៀតនៃយុទ្ធសាស្ត្រកំណែទម្រង់ ក៏ទទួលបានជោគជ័យដែរ។ ទាំងនេះរួមមានៈ ការបញ្ចូលការអប់រំអំពីសិទ្ធិមនុស្សទៅក្នុងកម្មវិធីសិក្សា ការបង្កើតមជ្ឈមណ្ឌលហ្វឹកហ្វឺនសម្រាប់មេធាវី ការពង្រឹងសមត្ថភាពក្រុមប្រឹក្សាក្រមសីលធម៌របស់គណៈមេធាវី ការអភិវឌ្ឍន៍សមត្ថភាពរបស់រាជបណ្ឌិតសភាវិជ្ជាជីវៈតុលាការ និងការបង្កើតប្រព័ន្ធឃ្លាំមើលវិស័យយុត្តិធម៌ ជាដើម។[22] ជាងនេះទៀត រាជរដ្ឋាភិបាលកម្ពុជា បើទោះបីជាមានការរិះគន់ខ្លះ នៅពេលថ្មីៗនេះ បានរុញច្បាប់សំខាន់ៗចំនួនបីដែលរង់ចាំយូរមកហើយ ឲ្យបានទទួលការអនុម័តដោយសភា ដូចដែលខ្លួនបានប្តេជ្ញានៅក្នុងផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ២០១៤-២០១៨។[23] ច្បាប់ទាំងបីនេះមាន៖ ច្បាប់ស្តីពីការរៀបចំអង្គការតុលាការ ច្បាប់ស្តីពីលក្ខន្តិកៈនៃចៅក្រម និងព្រះរាជអាជ្ញា និងច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រម។[24]

ក្រៅពីនេះ រាជរដ្ឋាភិបាលក៏បានខិតខំលើកកម្ពស់ហេដ្ឋារចនាសម្ព័ន្ធនៃប្រព័ន្ធយុត្តិធម៌។ នៅចន្លោះឆ្នាំ២០០៩ និង២០១៣ រាជរដ្ឋាភិបាលបានរៀបចំបង្កើតឲ្យមានតុលាការនៅខេត្តចំនួនពីរ(ប៉ៃលិន និងឧត្តរមានជ័យ)

---

[21] RGC, Rectangular Strategy Phase III, p. 14

[22] The Danish Institute for Human Rights (DIHR), "Implementation of Legal and Judiciary Reform in Cambodia," The Evaluation of DIHR Partnership Programme with General Secretariat of Council of Legal and Judicial Reform (CLJR), 2012, pp. 12-13.

[23] RGC, National Strategic Development Plan 2014-2018, p. 108.

[24] The Phnom Penh Post, accessed 13 February 2016, http://www.phnompenhpost.com/national/cpp-passes-judicial-laws-senate.

និងបានសាងសង់អាគារចំនួន៧ និងជួសជុលអាគារចំនួន៣ សម្រាប់តុលាការនៅតាមខេត្ត។[25] ប៉ុន្តែ ជាក់ស្តែង កិច្ចខិតខំប្រឹងប្រែងផ្នែកនេះជាបន្ត គឺជារឿងចាំបាច់ណាស់។ ត្រង់ចំណុចផ្សេងទៀត ក្រសួងយុត្តិធម៌បានបង្កើតយន្តការតុលាការគំរូ ដើម្បីគ្រប់គ្រងការចុះបញ្ជីសំណុំរឿងក្តី (ឧទាហរណ៍ គ្រប់គ្រងស្ថិតិ ពិនិត្យបន្ថែមប្រមូល ស្រាវជ្រាវ និងផ្តល់ព័តមានអំពីរឿងក្តី) ក្នុងគោលបំណងដើម្បីឲ្យតុលាការទាំងអស់មានស្តង់ដារដូចគ្នា។[26] ជាលទ្ធផល សៀវភៅចុះបញ្ជីសំណុំរឿងក្តីព្រហ្មទណ្ឌ និងសៀវភៅចុះបញ្ជីសំណុំរឿងក្តីរដ្ឋប្បវេណីចំនួន២៧ ត្រូវបានបង្កើតឡើង។ វគ្គបណ្តុះបណ្តាលចុះបញ្ជីសំណុំរឿងក្តី ក៏ត្រូវបានផ្តល់ជូនដល់ចៅក្រម ព្រះរាជអាជ្ញា ក្រឡាបញ្ជី និងមន្ត្រីយុត្តិធម៌នៅតុលាការខេត្តក្រុង។

ប៉ុន្តែ ការផ្លាស់ប្តូរទាំងនេះនៅក្នុងវិស័យច្បាប់ និងយុត្តិធម៌ គឺមិនសូវជាបានឃើញជាសាធារណៈទេ ព្រោះកំណែទម្រង់ច្បាប់ និងស្ថាប័ន អាចកើតឡើងដោយមិនមានផ្សព្វផ្សាយជាសាធារណៈច្រើន។[27] ហេតុផលនេះតម្រូវឲ្យរាជរដ្ឋាភិបាលកម្ពុជាបង្កើនកម្មវិធីផ្សព្វផ្សាយសាធារណៈ ដើម្បីជូនដំណឹងដល់ពលរដ្ឋអំពីកិច្ចខិតខំប្រឹងប្រែងនិងការប្តេជ្ញាចិត្តក្នុងការធ្វើកំណែទម្រង់ប្រព័ន្ធយុត្តិធម៌និងច្បាប់នៅកម្ពុជាប្រកបដោយទំនុកចិត្ត។[28]

## ៣. បញ្ហាប្រឈម និងសំណើរគោលនយោបាយ

បើទោះបីជាទទួលបានជោគជ័យខ្លាំងក៏ដោយនៅក្នុងការលើកកម្ពស់ប្រព័ន្ធច្បាប់ និងយុត្តិធម៌នៅកម្ពុជា បញ្ហាប្រឈមនៅតែមាន។

### *៣.១. បញ្ហាប្រឈមនៅក្នុងកំណែទម្រង់ច្បាប់ និងយុត្តិធម៌*

ផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ២០១៤-២០១៨ បានកំណត់បញ្ហាប្រឈមដូចខាងក្រោមនេះទាក់ទងនឹងការអនុវត្តយុទ្ធសាស្ត្រកំណែទម្រង់ច្បាប់និងវិស័យយុត្តិធម៌នេះ។ បញ្ហាប្រឈមនេះត្រូវបានចាត់ចូលជាពីរក្រុមដូចខាងក្រោមនេះ៖[29]

- ធនធានមនុស្ស

[25] RGC, National Strategic Development Plan 2014-2018, pp. 9-12.
[26] RGC, National Strategic Development Plan 2014-2018, pp. 9-12.
[27] Peng, Hor; Phallack, Kong & Menzel, Jorg. 2012. *Introduction to Cambodian Law*. Published by Konrad-Adenauer-Stiftung. P. 21.
[28] Ibid.
[29] RGC, National Strategic Development Plan 2014-2018, pp. 9-12.

- កង្វះខាតចៅក្រម ព្រះរាជអាជ្ញា ក្រឡាបញ្ជី និងមន្ត្រីរដ្ឋបាលនៅក្រសួងយុត្តិធម៌ និង នៅតុលាការខេត្តក្រុង។
- កង្វះខាតចៅក្រមមានសមត្ថភាពគ្រប់គ្រាន់សម្រាប់តុលាការការងារ តុលាការអនីតិជន តុលាការពាណិជ្ជកម្ម និងតុលាការរដ្ឋបាល។
- កង្វះខាតមន្ត្រីចុះបញ្ជីសំណុំរឿងក្តី (គម្រោងតុលាការគំរូ)។

▪ ការគ្រប់គ្រងសមត្ថភាពស្ថាប័ន:
  - កង្វះខាតអាគារការិយាល័យនៅក្នុងក្រសួង និងតុលាការខេត្ត និងកន្លែងស្នាក់នៅ និងការិយាល័យសម្រាប់ចៅក្រម និងព្រះរាជអាជ្ញា។
  - កង្វះខាតអាគារសម្រាប់យន្តការដោះស្រាយវិវាទក្រៅប្រព័ន្ធតុលាការ។
  - ថវិកាមានកំណត់សម្រាប់ក្រសួងយុត្តិធម៌ និងតុលាការខេត្តក្រុង។
  - កង្វះខាតមេធាវីសម្រាប់ផ្តល់ជំនួយផ្នែកច្បាប់។
  - កង្វះថវិកាសម្រាប់ដំណើរការសំណុំរឿងព្រហ្មទណ្ឌ។
  - មធ្យោបាយធ្វើដំណើរបេសកកម្មមានកំណត់។

ការប្តេជ្ញាចិត្តនិងអន្តរាគមន៍បន្ថែមទៀត គឺត្រូវការជាចាំបាច់ដើម្បីពង្រឹងនីតិរដ្ឋ ក៏ដូចជាវិស័យច្បាប់ និងតុលាការ នៅឆ្នាំខាងមុខៗ។ រាជរដ្ឋាភិបាលកម្ពុជាបានសម្តែងនូវចេតនាដើម្បីដោះស្រាយបញ្ហាប្រឈមទាំងនេះ ដើម្បីឲ្យទទួលបានលទ្ធផលច្រើនជាងនេះទៀត។ ការប្តេជ្ញាចិត្តនេះ អាចរកឃើញនៅក្នុងយុទ្ធសាស្ត្រដូចជា "កម្មវិធីនយោបាយ"របស់រាជរដ្ឋាភិបាលកម្ពុជានីតិកាលទី៥ នៃរដ្ឋសភា យុទ្ធសាស្ត្រចតុកោណដំណាក់កាលទី៣ និងផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ២០១៤-២០១៨ ជាដើម។

## *៣.២. សំណើរគោលនយោបាយ*

បញ្ហាប្រឈមដែលបានកំណត់ដោយរាជរដ្ឋាភិបាល នឹងតម្រូវឲ្យមានការប្តេជ្ញាចិត្ត ការច្នៃប្រឌិត ពេលវេលា និងធនធាន ដើម្បីនាំមកនូវការផ្លាស់ប្តូរធំដុំនៅក្នុងកំណែទម្រង់ច្បាប់ និងតុលាការ។

▪ ធនធាន និងថវិកា គឺជាបញ្ហាប្រឈមដ៏ធំចំពោះកិច្ចខិតខំប្រឹងប្រែងកំណែទម្រង់វិស័យយុត្តិធម៌នៅកម្ពុជា។ បញ្ហាប្រឈមនេះ គឺជាបញ្ហាប្រឈមដ៏ធំបំផុតមួយនៅក្នុងចំណោមបញ្ហាប្រឈមទាំងឡាយដែលរាជរដ្ឋាភិបាលត្រូវតែជំនះ។ រាជរដ្ឋាភិបាលបានដោះស្រាយបញ្ហានេះខ្លះៗហើយ តាមរយៈការបង្កើនថវិកាជាបណ្តើរៗមកឲ្យវិស័យយុត្តិធម៌។ កង្វះខាតថវិការបស់តុលាការ ក៏ដូចជាប្រាក់បៀវត្សរ៍

ប្រាក់សោធននិវត្តន៍ និងផលប្រយោជន៍បន្ថែម បានបង្កជាការលំបាកយ៉ាងខ្លាំងដល់មន្ត្រីនៅក្នុងវិស័យយុត្តិធម៌ ក្នុងការបំពេញភារកិច្ចរបស់ខ្លួន ហើយការនេះឯងដែលធ្វើឲ្យពួកគាត់ងាយទាក់ទាញឲ្យចូលរួមទទួលសំណូកសូកប៉ាន់។[30]

- វាមានភាពចាំបាច់ក្នុងការបង្កើនទាំងចំនួន និងសមត្ថភាពរបស់ចៅក្រម និងព្រះរាជអាជ្ញា ជាពិសេសនៅតាមតំបន់ជនបទ។ បច្ចុប្បន្ននេះ ចៅក្រមនៅកម្ពុជាមានចំនួនតែ២៦៤នាក់ ពោលគឺ១,៧៦នាក់ក្នុងចំនួនប្រជាជនមួយសែននាក់។[31] បើយើងប្រៀបធៀបទៅនឹងប្រទេសបារាំង និងអាឡឺម៉ង់ ប្រទេសបារាំងមានចៅក្រមចំនួន៨,៥៥នាក់ និងប្រទេសអាឡឺម៉ង់ មានចៅក្រមចំនួន៤,៤៦នាក់ នៅក្នុងចំនួនប្រជាជនមួយសែននាក់ដូចគ្នា។ ជាងនេះទៀត ចៅក្រម ភាគច្រើន គឺនៅទីក្រុងភ្នំពេញ។[32] ចំនួនចៅក្រមមិនគ្រប់គ្រាន់នេះ អាចបណ្តាលឲ្យមានការពន្យានីតិវិធីសវនាការ។ ដូច្នេះ ការបង្កើនចំនួនចៅក្រម និងមន្ត្រីក្នុងវិស័យយុត្តិធម៌ គឺមានសារសំខាន់ណាស់ ជាពិសេសនៅតាមតំបន់ជនបទ។ ការបង្កើតរាជបណ្ឌិតសភាវិជ្ជាជីវៈតុលាការ និងមជ្ឈមណ្ឌលហ្វឹកហ្វឺនមេធាវី គឺជាជំហានដ៏ត្រឹមត្រូវមួយនៅក្នុងកំណែទម្រង់នេះ។

- ទិន្នន័យមានកំណត់ទាក់ទងនឹងវិស័យយុត្តិធម៌ អាចប៉ះពាល់ដល់កំណែទម្រង់វិស័យនេះ។ នៅពេលខ្វះខាតទិន្នន័យ វាមានការលំបាកក្នុងការធ្វើការវាយតម្លៃអំពីប្រសិទ្ធិភាពរបស់វិស័យយុត្តិធម៌។ ដូច្នេះ ទិន្នន័យរួមមួយគួរត្រូវបង្កើតឡើងដើម្បីតាមដានព័ត៌មានតុលាការដូចជាចំនួនសំណុំរឿង ចំនួនសំណុំរឿងដោះស្រាយរួច និង ជាមធ្យម រយៈពេលប៉ុន្មានដែលត្រូវចំណាយសម្រាប់សំណុំរឿងនីមួយៗ។ ដើម្បីបង្កើតប្រព័ន្ធទិន្នន័យនេះ រាជរដ្ឋាភិបាលកម្ពុជា ជាពិសេស ក្រសួងយុត្តិធម៌ អាចបំពេញការងារនេះជាមួយម្ចាស់ជំនួយ និងអង្គការមិនមែនរដ្ឋាភិបាល។ ជាងនេះទៀត ដើម្បីបង្កើនតម្លាភាព ទិន្នន័យនេះគួរតែបញ្ចេញជាសាធារណៈ។[33]

---

[30] International Bar Association, "Justice versus corruption Challenges to the independence of the judiciary in Cambodia," Report of the International Bar Association's Human Rights Institute, 2015, p. 35. *IBAHRI meeting with the Vice President of the Supreme Court, 22 April 2015.*

[31] Ibid.

[32] Ibid., p. 36.

[33] East-West Management Institute, "Legal Reform: Program on Rights and Justices in Cambodia II (2013-2018)," accessed 16 February 2016, http://ewmi.org/sites/ewmi.org/files/files/programpdfs/EWMICambodiaPRAJII2009.pdf.

- អំពើពុករលួយនៅក្នុងវិស័យយុត្តិធម៌ ជាបញ្ហាមិនមែនសម្រាប់តែកម្ពុជាទេ ប៉ុន្តែ ជាបញ្ហារបស់ប្រទេសជាច្រើន ជាពិសេសប្រទេសកំពុងអភិវឌ្ឍន៍។[34] នៅក្នុងសិក្ខាសាលាស្តីអំពីសុចរិតភាពរបស់ចៅក្រមនៅក្នុងខែកក្កដា ឆ្នាំ២០១២ រដ្ឋមន្ត្រីក្រសួងយុត្តិធម៌បានសង្កត់ធ្ងន់ថា "ការបាត់បង់ភាពស្មោះត្រង់នៅក្នុងវិជ្ជាជីវៈតុលាការបានបណ្តាលឲ្យបាត់បង់ទំនុកចិត្តរបស់សាធារណៈជនទៅលើប្រព័ន្ធតុលាការ"។[35] ដូច្នេះ ពង្រឹងក្រមសីលធម៌វិជ្ជាជីវៈ និងការដាក់វិន័យចៅក្រម ជារឿងសំខាន់បំផុត។ ការពង្រឹងនេះអាចធ្វើឡើងតាមរយៈ ការផ្តល់វគ្គបណ្តុះបណ្តាលជាបន្តបន្ទាប់សម្រាប់ទាំងចៅក្រម និងព្រះរាជអាជ្ញា។[36] ការពង្រឹងនេះក៏អាចធ្វើឡើងតាមរយៈការអនុវត្តច្បាប់ពាក់ព័ន្ធនឹងក្រមសីលធម៌វិជ្ជាជីវៈរបស់មន្ត្រី និងសមាជិកវិស័យយុត្តិធម៌។ រាជរដ្ឋាភិបាលបានប្តេជ្ញាចិត្តក្នុងការប្រយុទ្ធប្រឆាំងនឹងអំពើពុករលួយ ហើយការប្តេជ្ញានេះនឹងជួយបង្កើនការបំពេញភារកិច្ចវិជ្ជាជីវៈរបស់តុលាការ និងមន្ត្រីតុលាការមិនខាន។[37]

- ការប្តេជ្ញារបស់រាជរដ្ឋាភិបាលកម្ពុជាក្នុងការពង្រីកសេវា និង ការប្រើប្រាស់យន្តការដោះស្រាយវិវាទក្រៅប្រព័ន្ធតុលាការ គួរតែត្រូវលើកទឹកចិត្ត។ នៅក្នុងចំណោមផលប្រយោជន៍ផ្សេងទៀត ការប្រើប្រាស់យន្តការនេះអាចកាត់បន្ថយការកកស្ទះសំណុំរឿងនៅតុលាការខេត្ត និងពន្លឿនដំណោះស្រាយ។ នៅចន្លោះឆ្នាំ២០០៦ និង២០១០ រាជរដ្ឋាភិបាលកម្ពុជា ក្រុមប្រឹក្សាកំណែទម្រង់ច្បាប់និងយុត្តិធម៌ ក្រសួងយុត្តិធម៌ និងក្រសួងមហាផ្ទៃ ដោយមានជំនួយហិរញ្ញវត្ថុពីកម្មវិធីអភិវឌ្ឍន៍សហប្រជាជាតិ (UNDP) និងទីភ្នាក់ងារអេស្ប៉ាញសម្រាប់ការអភិវឌ្ឍន៍ និងកិច្ចសហប្រតិបត្តិការអន្តរជាតិ (AECID) បានអនុវត្តគម្រោង "Access to Justice Project"។ ផ្នែកមួយរបស់គម្រោងនេះគឺការបង្កើតប្រព័ន្ធដោះស្រាយវិវាទក្រៅតុលាការ ដែលហៅថា "ផ្ទះយុត្តិធម៌ (Maisons de la Justice)" នៅថ្នាក់ស្រុក និង គណៈកម្មាធិការដោះស្រាយវិវាទឃុំ (Commune Dispute Resolution Committee)" នៅ

---

[34] UNODC and Crime Prevention, "Strengthening Judicial Integrity Against Corruption," Global Programme Against Corruption Conference, 2001, p. 4.

[35] UNODC, accessed 16 February 2016, https://www.unodc.org/southeastasiaandpacific/en/cambodia/2012/07/judicial-integrity/story.html.

[36] International Bar Association, "Justice versus corruption Challenges to the independence of the judiciary in Cambodia," Report of the International Bar Association's Human Rights Institute, 2015.

[37] See, in particular, Rectangular Strategy Phase III, National Strategic Development Plan 2014-2018, and Political Platform of the Fifth Legislature of the National Assembly.

ថ្នាក់ឃុំ។[38] យន្តការទាំងពីរនេះ បានផ្តល់នូវជម្រើសដោះស្រាយវិវាទក្រៅតុលាការ។ គិតត្រឹមឆ្នាំ ២០១០ មានផ្ទះយុត្តិធម៌ចំនួន២០ និងគណៈកម្មាធិការដោះស្រាយវិវាទឃុំចំនួន៥៦ នៅទូទាំងប្រទេស។ ការវាយតម្លៃគម្រោងនេះ ដោយកុងស៊ុលតង់ឯករាជ្យ Laura McGrew និង Virorth Doung បានវាយតម្លៃផ្នែកនេះថាបានទទួលជោគជ័យ បើទោះបីជាមានបញ្ហាប្រឈមខ្លះក៏ដោយ និងបានផ្តល់អនុសាសន៍ឲ្យពង្រីកយន្តការនេះបន្ថែម។ ចាប់ពីនោះមក រាជរដ្ឋាភិបាលកម្ពុជាបានបង្កើតមណ្ឌលបន្ថែមចំនួន៣១ទៀត។[39]

- ចំនួនតុលាការឧទ្ធរណ៍គួរតែត្រូវបន្ថែម។ នៅប្រទេសកម្ពុជាមានតុលាការឧទ្ធរណ៍តែមួយប៉ុណ្ណោះ និងមានទីតាំងនៅភ្នំពេញ។ ដូច្នេះ ប្រជាពលរដ្ឋក្រីក្រ និងរស់នៅជនបទ ដែលពិបាកធ្វើដំណើរ មានលទ្ធភាពប្រើប្រាស់តុលាការឧទ្ធរណ៍នេះមានកម្រិត។ ជាងនេះទៀត វាហាក់បីដូចជាមិនមានច្បាប់កំណត់អំពីហេតុផលសម្រាប់ធ្វើបណ្តឹងឧទ្ធរណ៍ទេ។[40] ដូច្នេះ ការកកស្ទះសំណុំរឿងនៅតុលាការឧទ្ធរណ៍ គឺជាការព្រួយបារម្ភធំមួយ។[41] រាជរដ្ឋាភិបាលកម្ពុជា បាននឹងកំពុងពិភាក្សាអំពីជម្រើសបង្កើតតុលាការឧទ្ធរណ៍បន្ថែមនៅតាមខេត្ត។[42] កិច្ចខិតខំប្រឹងប្រែងនេះ នឹងមិនត្រឹមតែធ្វើឲ្យប្រជាពលរដ្ឋក្រីក្រនិងអ្នករស់នៅតាមជនបទ អាចមានលទ្ធភាពប្រើប្រាស់តុលាការឧទ្ធរណ៍ទេ ថែមទាំងកាត់បន្ថយការកកស្ទះសំណុំរឿងនៅចំពោះមុខតុលាការឧទ្ធរណ៍បច្ចុប្បន្នទៀតផង។

- ពន្ធនាគារនៅប្រទេសកម្ពុជា មានចំនួនអ្នកទោសច្រើនហួសលទ្ធភាព។[43] ការនេះបានបង្កជាបញ្ហាមិនត្រឹមតែលទ្ធភាពក្នុងការទទួលផ្ទុកចំនួនអ្នកទោសទេ ថែមទាំងបញ្ហាសង្គមផងដូចជាសុខភាព អនាម័យ និងការរាប់អានមនុស្សមិនល្អនៅក្នុងពន្ធនាគារទៀតផង។ ដើម្បីកាត់បន្ថយចំនួនអ្នកទោសតុលាការគួរ

---

[38] Laura McGrew and Virorth Doung, "Final Evaluation Report of Access to Justice Project in Cambodia," May 2010.

[39] National Strategic Development Plan 2014-2018, p. 11; See also, Laura McGrew and Virorth Doung, "Final Evaluation Report of Access to Justice Project in Cambodia," May 2010.

[40] Koy Neam, *Introduction to the Cambodian Judicial Process*, The Asia Foundation: 1998.

[41] Khuon Narim and Lauren Crothers, "Ministries Discuss New Appeals Courts, Judicial Reform," The Cambodia Daily, 22 January 2014, accessed 18 February 2016, https://www.cambodiadaily.com/archives/ministries-discuss-new-appeal-courts-judicial-reform-50940/.

[42] Khy Sovuthy, "Government to Establish New Appeal Court by 2018," The Cambodia Daily, 18 February 2016, accessed 18 February 2016, https://www.cambodiadaily.com/news/government-to-establish-new-appeal-court-by-2018-108673/.

[43] OHCHR, Prison Reform Support Programme in Cambodia, accessed 18 February 2016, http://cambodia.ohchr.org/EN/PagesFiles/PrisonIndex.htm.

តែមានភាពច្នៃប្រឌិតនៅក្នុងការអនុវត្តទោសទណ្ឌ។ ជាឧទាហរណ៍ បស្ចឹមប្រទេសអនុវត្តទណ្ឌកម្មបម្រើការងារសហគមន៍ (community service) និងយន្តការដោះស្រាយវិវាទក្រៅប្រព័ន្ធតុលាការយ៉ាងហោចណាស់សម្រាប់បទល្មើសស្រាលៗ។ ការធ្វើបែបនេះនឹងជួយកាត់បន្ថយចំនួនអ្នកទោសនៅក្នុងពន្ធនាគារ និងអាចឲ្យរដ្ឋាភិបាលប្រើប្រាស់ថវិកាពន្ធនាគារសម្រាប់កម្មវិធីសំខាន់ផ្សេង។

## សេចក្តីសន្និដ្ឋាន

ច្បាប់ និងប្រព័ន្ធយុត្តិធម៌នៅកម្ពុជា ត្រូវបានលើកកម្ពស់ជាបន្តបន្ទាប់ តាមរយៈកំណែទម្រង់ផ្សេងៗ។ បន្ទាប់ពីបង្កើតយុទ្ធសាស្រ្ត និងផែនការសកម្មភាពសម្រាប់កំណែទម្រង់ច្បាប់ និងយុត្តិធម៌ រាជរដ្ឋាភិបាលកម្ពុជា រហូតមកដល់បច្ចុប្បន្ននេះ បានសម្រេចបាននូវជោគជ័យសំខាន់ជាច្រើន។ ប៉ុន្តែ បញ្ហាប្រឈមនៅតែមាន និងតម្រូវឲ្យមានចំណាត់ការ និងគោលនយោបាយបន្ថែមជាបន្តបន្ទាប់ ដើម្បីធានាឲ្យបាននូវប្រព័ន្ធយុត្តិធម៌ និងច្បាប់ដែលមានតម្លាភាព។ ចំណាត់ការ និងគោលនយោបាយទាំងនោះអាចរួមមាន៖ បង្កើនចំនួនចៅក្រម និងព្រះរាជអាជ្ញា បង្កើតប្រព័ន្ធកត់ត្រាទិន្នន័យវិស័យច្បាប់និងយុត្តិធម៌ បង្កើនប្រាក់បៀវត្សរ៍ចៅក្រម និងមន្រ្តីតុលាការ និងបង្កើនថវិកាតុលាការ និងបង្កើនក្រមសីលធម៌តុលាការតាមរយៈវគ្គបណ្តុះបណ្តាល និងការអនុវត្តច្បាប់។ កិច្ចខិតខំប្រឹងប្រែងក្នុងការពង្រីកការប្រើប្រាស់យន្តការដោះស្រាយវិវាទក្រៅប្រព័ន្ធតុលាការ គួរតែត្រូវបង្កើនបន្ថែម ដើម្បីកាត់បន្ថយនូវការកកស្ទះសំណុំរឿងនៅតាមតុលាការខេត្តក្រុង ហើយតាមរយៈនេះ ក៏អាចកាត់បន្ថយការស្ទះសំណុំរឿងដែលកំពុងរង់ចាំសវនការ។ ការដោះស្រាយវិវាទក្រៅប្រព័ន្ធតុលាការក៏អាចជួយកាត់បន្ថយចំនួនអ្នកទោស ដែលកំពុងតែកកស្ទះនៅតាមពន្ធនាគារនៅទូទាំងប្រទេសដែរ។ ដោយការកាត់បន្ថយចំនួនអ្នកទោសដែលមិនចាំបាច់នៅតាមពន្ធនាគារ រដ្ឋអាចយកថវិកាសម្រាប់ពន្ធនាគារនេះប្រើប្រាស់សម្រាប់កម្មវិធីសំខាន់ផ្សេងទៀតរបស់ជាតិ។

# បញ្ជីឯកសារយោង


- Anukret on Organization and Function of MoJ (2000)
- Constitution of Kingdom of Cambodia
- Destination Justice, accessed 14 February 2016, http://www.chbab.net/chbab-net-in-english/about-the-cambodian-legal-system-en.
- East-West Management Institute, "Legal Reform: Program on Rights and Justices in Cambodia II (2013-2018)," accessed 14 February 2016, http://ewmi.org/sites/ewmi.org/files/files/programpdfs/EWMICambodiaPRAJII2009.pdf.
- International Bar Association, "Justice versus corruption Challenges to the independence of the judiciary in Cambodia," Report of the International Bar Association's Human Rights Institute, 2015.
- Khuon Narim and Lauren Crothers, "Ministries Discuss New Appeals Courts, Judicial Reform," The Cambodia Daily, 22 January 2014, accessed 18 February 2016, https://www.cambodiadaily.com/archives/ministries-discuss-new-appeal-courts-judicial-reform-50940/.
- Khy Sovuthy, "Government to Establish New Appeal Court by 2018," The Cambodia Daily, 18 February 2016, accessed 18 February 2016, https://www.cambodiadaily.com/news/government-to-establish-new-appeal-court-by-2018-108673/.
- Koy Neam, *Introduction to the Cambodian Judicial Process*, The Asia Foundation: 1998.
- Laura McGrew and Virorth Doung, "Final Evaluation Report of Access to Justice Project in Cambodia," May 2010.
- Law on Establishment of Ministry of Justice (1996)
- Law on Judicial Organization (2014)
- Law on Organization and Functioning of Supreme Council of Magistracy (2014)
- National Strategic Development Plan 2014-2018
- OHCHR, Prison Reform Support Programme in Cambodia, accessed 18 February 2016, http://cambodia.ohchr.org/EN/PagesFiles/PrisonIndex.htm.

- Peng, Hor; Phallack, Kong & Menzel, Jorg. 2012. *Introduction to Cambodian Law*. Published by Konrad-Adenauer-Stiftung.
- Political Platform of the Fifth Legislature of the National Assembly.
- Rectangular Strategy Phase III
- The Danish Institute for Human Rights (DIHR), "Implementation of Legal and Judiciary Reform in Cambodia," The Evaluation of DIHR Partnership Programme with General Secretariat of Council of Legal and Judicial Reform (CLJR), 2012.
- Tom Fawthrop and Helen Jarvis, trans., *Getting away with Genocide?, Elusive Justice and the Khmer Rouge Tribunal,* (Sydney: UNSW Press, 2005).
- UNODC and Crime Prevention, "Strengthening Judicial Integrity Against Corruption," Global Programme Against Corruption Conference, 2001.
- The Phnom Penh Post, accessed 13 February 2016, http://www.phnompenhpost.com/national/cpp-passes-judicial-laws-senate.
- UNODC, accessed 16 February 2016, https://www.unodc.org/southeastasiaandpacific/en/cambodia/2012/07/judicial-integrity/story.html.